ទីស្តីការក្រសួងយុត្តិធម៌
លេខ ០១ .ព្រទ/សរ/៩៨

# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

# សារាចរ

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

**ផ្ញើមក**

**អស់លោកប្រធានតុលាការខេត្ត-ក្រុង**
**អស់លោកព្រះរាជអាជ្ញាអមតុលាការខេត្ត-ក្រុង**

**កម្មវត្ថុ:** អំពីការចោទប្រកាន់ជនប្រព្រឹត្តល្មើសក្នុងសំណុំរឿងព្រហ្មទណ្ឌ ។

កន្លងមកចំណាត់ការដោះស្រាយសំណុំរឿងព្រហ្មទណ្ឌសឹងតែទាំងអស់ លោកព្រះរាជអាជ្ញា និងលោកចៅក្រមខ្លះច្រើនធ្វើការចោទប្រកាន់តែលើបទល្មើសណា ដែលមានព្យសនកម្មជាលេចធ្លោជាងគេពុំបានគិតដល់បទល្មើសផ្សេងៗទៀត ដែលជនល្មើសដដែល និងគូកនមានរូបព្រឹត្តផងទេ ឧទាហរណ៍ ចំណាត់ការដោះស្រាយសំណុំរឿងព្រហ្មទណ្ឌលេខ ១៨៦ ចុះថ្ងៃទី១៥-០៨-៩៦ របស់តុលាការខេត្តកំពង់ចាម គឺធ្វើការចោទប្រកាន់តែលើបទល្មើសប្លន់ទ្រព្យសម្បត្តិប្រជាជនកាលពីថ្ងៃទី១៣-០៨-៩៦ ប្រព្រឹត្តនៅភូមិជីមាន់ជើង សង្កាត់ក្រែ ស្រុកពញាក្រែក ខេត្តកំពង់ចាម ប៉ុន្តែពុំបានធ្វើការចោទប្រកាន់ពីបទលួចកាំភ្លើង AK ស្វាយបទរបស់បញ្ជាការប៉ុស្តិ៍នគរបាលកូនជ្រូក ឈ្មោះ ម៉ែន មិល ដើម្បីយកទៅប្រព្រឹត្តខាងលើនេះ ។

អំណើះតទៅ សូមអស់លោកពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយលើបទល្មើសទាំងអស់ដែលបានកើតមានឡើង ធ្វើការចោទប្រកាន់ឱ្យបានគ្រប់បទល្មើសដែលជនល្មើសបានប្រព្រឹត្ត ដើម្បីបង្ក្រាបអំពើល្មើសទាំងអស់ដើម្បីការពារសណ្តាប់ធ្នាប់សាធារណៈនិងសន្តិសុខសង្គមឱ្យបានដាច់ខាត ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៨

**រដ្ឋមន្ត្រី**

**ចែម ស្គួន**

ចម្លងជូន
-តុលាការកំពូល
-មហាអយ្យការអមតុលាការកំពូល
-សាលាឧទ្ធរណ៍
-មហាអយ្យការអមសាលាឧទ្ធរណ៍
-ដើម្បីជ្រាប